


# សហគមន៍ សិទ្ធិមនុស្ស និងយេនឌ័រ (CRG) កម្មវិធីជំនួយបច្ចេកទេស (TA)

ជំនួយបច្ចេកទេសសំរាប់សហគមន៍ សិទ្ធិមនុស្ស និងយេនឌ័រ (CRG TA) ត្រូវបានបង្កើតឡើងដើម្បីជួយដល់អង្គការសង្គមស៊ីវិលនិងអង្គការសហគមន៍និងបណ្តាញដើម្បីធានាថាឧបសគ្គទាក់ទងនឹងសិទ្ធិមនុស្ស និងយេនឌ័រត្រូវបានលើកយកមកនិយាយដោយមូលនិធិសកល។
.

## តើនរណាខ្លះអាចមានសិទ្ធិដាក់ពាក្យក្នុងកម្មវិធី CRG TA?

- បណ្តាញអង្គការសង្គមស៊ីវិលក្នុងស្រុកឬថ្នាក់ជាតិ
- បណ្តាញអង្គការក្នុងស្រុកឬថ្នាក់ជាតិ នៃមនុស្សដែលរងផលប៉ះពាល់ដោយជំងឺ (ឧទាហរណ៍ ប្រជាជនងាយរងគ្រោះ ស្ត្រី យុវជន អ្នករស់នៅជាមួយមេរោគអេដស៍ សហគមន៍ដែលរងផលប៉ះពាល់ពីជំងឺរបេង និង / ឬ សហគមន៍ដែលរងគ្រោះដោយជំងឺគ្រុនចាញ់)
- CCMs ប្រសិនបើពួកគេសហការជាមួយក្រុមដទៃទៀតសម្រាប់ទាំងការអភិវឌ្ឍនិងការដាក់ពាក្យស្នើសុំ

## តើខ្ញុំអាចដាក់ពាក្យស្នើរសុំនៅពេលណា?

កម្មវិធីនេះត្រូវបានគេកែទម្រង់ហើយឥឡូវនេះអ្នកអាចទទួលបានជំនួយបច្ចេកទេស CRG TA **នៅគ្រប់ដំណាក់កាលនៃជំនួយ** ដែលរួមបញ្ចូលទាំងការអនុវត្តជំនួយ។ កម្មវិធីនេះក៏គាំទ្រផងដែរដល់ការចូលរួមរបស់សហគន៍នៅក្នុងដំណើរការនៃការធ្វើអន្តរកាល និងការធ្វើផែនការ និរន្តរភាព ក៏ដូចជាការផ្តល់មូលនិធិ (STC) ឬដំណើរការមូលនិធិសកលផ្សេងទៀត ដោយគិតទាំងការរៀបចំ និងបង្កើតផែនការយុទ្ធសាស្ត្រជាតិ (NSP) ជាដើម។

## តើជំនួយបច្ចេកទេសប្រភេទណាដែលខ្ញុំអាចស្នើសុំបាន?

អ្នកអាចដាក់ពាក្យស្នើសុំក្នុងកម្មវិធី CRG TA សម្រាប់គម្រោងដែលទាក់ទងទៅនឹង:

- ការវិភាគស្ថានភាពនិងការវាយតម្លៃតម្រូវការ (រួមបញ្ចូលទាំងការវាយតម្លៃអំពីយេនឌ័រ)
- ការចូលរួមក្នុងកិច្ចសន្ទនាក្នុងប្រទេស
- គាំទ្រការរៀបចំកម្មវិធី
- គាំទ្រដល់ការត្រួតពិនិត្យនិងឃ្លាំមើលការអនុវត្តជំនួយនិងរៀបចំកម្មវិធីឡើងវិញ
- ការចូលរួមក្នុងយុទ្ធសាស្រ្តនិរន្តរភាព ការធ្វើអន្តរកាល និងការចូលរួមមូលនិធិ

នេះមានន័យថាជំនួយបច្ចេកទេសសំរាប់គាំទ្រឬការពង្រឹងស្ថាប័ន**មិនអាច**ត្រូវបានផ្តល់ជូនតាមរយៈកម្មវិធីជំនួយបច្ចេកទេស CRG TA ឡើយ។



## តើនរណាជាអ្នកផ្ដល់ជំនួយបច្ចេកទេស CRG TA?

នាយកដ្ឋាន CRG នៃលេខាធិការដ្ឋានមូលនិធិសកលបានផ្ដល់ការគាំទ្រជាមុនដល់អ្នកផ្ដល់សេវាជំនួយបច្ចេកទេសចំនួន 25 នាក់។ អ្នកអាចស្នើសុំអ្នកផ្ដល់សេវាជាក់លាក់ពីបញ្ជីនៅក្នុងពាក្យសុំរបស់អ្នក ប៉ុន្តែនាយកដ្ឋាន CRG ជាអ្នកធ្វើការសំរេចចិត្តចុងក្រោយ។

## តើខ្ញុំអាចដាក់ពាក្យសុំបានយ៉ាងដូចម្ដេច?

ដើម្បីដាក់ពាក្យសុំ អ្នកត្រូវទាញយកទម្រង់ពាក្យសុំនៅ **https://www.theglobalfund.org/media/5626/fundingmodel_crgtechnicalassistancerequest_form_en.docx?u=636486807400000000**. បំពេញវាហើយផ្ញើទៅកាន់ **CRGTA@theglobalfund.org**.

ឬ អ្នកក៏អាចទាក់ទង APCRG ទៅ **jenho@apcaso.org** (អ្នកគ្រប់គ្រងកម្មវិធី), **quentinbatreau@apcaso.org** (អ្នកសម្របសម្រួល) ឬ **jeffacaba@apcaso.org**(អ្នកទំនាក់ទំនង) ។

## បញ្ជីអ្នកផ្ដល់សេវា CRG TA ដែលបានអនុម័ត និងគាំទ្រ

African Men for Sexual Health and Rights (AMSHeR)
AIDS & Rights Alliance for Southern Africa (ARASA)
AIDS Strategy, Advocacy and Policy (ASAP)
Alliance India*
Alliance Technical Assistance Centre - International Charitable Foundation (ATAC-ICF)
International HIV/AIDS Alliance
Amref
APCOM* Asia
Catalyst*
ATHENA
Australian Federation of AIDS Organisations (AFAO)*
Canadian HIV/AIDS Legal Network
Caribbean Vulnerable Communities Coalition (CVC)
Community Leadership and Action Collaborative (CLAC) - a collaboration between GNP+, GATE, NSWP, INPUD, and IRGT
Eurasian Coalition on Male Health (ECOM)
HIVOS
International Center for Research on Women (ICRW)
International Council of AIDS Service Organisations (ICASO)
KELIN
KeNAAM
Moldovan Institute for Human Rights (IDOM)
Nai Zindagi
Networking HIV & AIDS Community of Southern Africa (NACOSA)
PATH
Speak Up Africa
The Union

* TA providers that are based in Asia Pacific

**APCASO** គឺជាបណ្ដាញសង្គមស៊ីវិលក្នុងតំបន់នៃសហគមន៍និងអង្គការក្រៅរដ្ឋាភិបាលស្ដីពីមេរោគអេដស៍ សុខភាពនិងយុត្តិធម៌សង្គម.

**APCASO Focal Points:** Australia:Australian Federation of AIDS Organisations (AFAO); Cambodia: HIV/AIDS Coordinating Committee

(HACC) and KHANA; China: China HIV/AIDS Information Network (CHAIN); Indonesia: GAYa NUSANTARA and Spiritia Foundation; India: National Coalition of People Living with HIV (NCPI+); Japan: Africa-Japan Forum; Lao PDR: Lao Positive Health Association (LaoPHA); Malaysia: PT Foundation; Philippines: Action for Health Initiatives (ACHIEVE); Pakistan: Association of People Living with HIV (APLHIV); Papua New Guinea: Igat Hope; Sri Lanka: Alliance Lanka; Vietnam: Centre for Supporting Community Development Initiatives (SCDI)

www.apcaso.org @Apcaso apcasoteam@apcaso.org